# ១៧

# ធម៌ព្រះពុទ្ធ តាមការយល់ និង ការពិសោធន៍ខ្លះ របស់ខ្ញុំ

*ជាបឋម ខ្ញុំសូម បញ្ជាក់ថា គំនិតយោបល់ ដែលខ្ញុំសូមជូនលោកអ្នកអានដូចតទៅនេះ ជាគំនិត និងយោបល់ផ្ទាល់ខ្លួនខ្ញុំ ដែលខ្ញុំបានយល់តាមប្រាជ្ញាខ្ញុំ នូវធម៌ព្រះពុទ្ធ ។ ដោយខ្ញុំជា បុថុជ្ជននៅឡើយ ការបកស្រាយនេះ អាចខុសពីធម៌ព្រះពុទ្ធដែលព្រះអង្គបានចែងទុកមក។ ខ្ញុំសរសេរនេះ គ្រាន់តែជាគំនិតមួយ សម្រាប់លោកអ្នកយកទៅពិចារណា ថា ត្រូវ ឬ ខុស ប៉ុណ្ណោះទេ។ ទុកជាអាហារមួយខាងផ្លូវចិត្ត ដែលខ្ញុំសូមជូនលោកអ្នក។*

*១-និព្វានតាមខ្ញុំយល់*

*ដោយនិព្វាន យើងមិនទាន់ទៅដល់ អ្នកខ្លះបកថាសូន្យ ជាពិសេសជនជាតិបរទេស ហើយខ្មែរយើងបកថា អមតៈមហានិព្វាន ជាស្ថានក្សេមផុតចាកទុក្ខ។ តែខ្ញុំសួរខ្លួនឯងថាហេតុអ្វីបានជាថា និព្វាន គឺ ផុតចាកទុក្ខ? ហើយកាលណាមិនទាន់សម្រេចនិព្វាននោះនៅមានទុក្ខ? បើធម៌ព្រះពុទ្ធ ជាធម្មជាតិ យើងត្រូវយល់បានដោយការសមហេតុសមផល ពោលគឺមិនមែនដោយជំនឿទាំងស្រុងនោះទេ ។*

*តាមព្រះពុទ្ធសាសនា មនុស្សយើងម្នាក់ៗ មានកាយនិងចិត្ត។ ដើម្បីថា យើងបានសុខទាល់ តែកាយក៏សុខ និង ចិត្តក៏សុខ។ កាយមិនសុខ កាលណាយើងមានរោគមកបៀតបៀនគឺថាមានមេរោគផ្សេងៗនៅក្នុងកាយយើង។ ដើម្បីកុំឲ្យមេរោគមកបៀតបៀនកាយបានទាល់តែយើងអត់មានកាយ ។ ហេតុនេះហើយបានជា មានព្រហ្មអត់រូប (អរូបព្រហ្ម) ដែលទៅអំពីព្រហ្មមានរូប ដោយខំធ្វើឈានតទៅទៀត ។ តែទុកជាព្រហ្មអត់រូបក៏ដោយក៏នៅតែដោះស្រាយ ជម្ងឺខាងផ្លូវចិត្តមិនទាន់បាន ពីព្រោះនៅមានមេរោគខាងផ្លូវចិត្តនៅឡើយ ដែលមកបៀតបៀនចិត្តនោះ។ មេរោគនោះ តាមព្រះពុទ្ធ គឺ តណ្ហា។ ដូច្នេះដើម្បី ចិត្តបានសុខ ទាល់តែចិត្តអស់តណ្ហារលីង គឺស្អាតបរិសុទ្ធ ។ និព្វាន នៅលើ*

ភពមនុស្សយើងនេះមាន គឺនិព្វានខាងផ្លូវចិត្ត បានដោយចិត្តអស់តណ្ហា។ តែនិព្វានខាងផ្លូវកាយ មិនទាន់សម្រេចទេ ពីព្រោះនៅមានកាយដែលជាសំបុកនៃរោគ នៅក្រោមច្បាប់ អនិច្ចំនៅឡើយ។ និព្វានខាងផ្លូវចិត្តយើងនឹងស្គាល់ កាលណាចិត្តយើងស្អាតបរិសុទ្ធ សក្បុសដូចក្រណាត់សំពត់ថ្មីដែលទើបនឹងចេញពីកីតម្បាញ។ កាលណាចិត្តមិនទាន់បានស្អាតទេ បើជាអរិយបុគ្គល ក៏នៅជាអរិយបុគ្គលថ្នាក់ដំបូង មិនទាន់ទៅដល់ថ្នាក់ព្រះអរហន្តនៅឡើយ ។ តែថ្វីបើមិនទាន់បានជាព្រះអរហន្តក៏ដោយ យើងអាចភ្លក់រសនិព្វានម្តងៗបានដែរ កាលណាចិត្តយើងស្ងប់ បរិសុទ្ធ ឥតមាន លោភៈ ទោសៈ មោហៈ មកលាយឡំ ។ យើងដែលខុសពីព្រះអរហន្តត្រង់ចិត្តយើងមិនបានបរិសុទ្ធរហូត ដូចជាយើងស្ងួតតែមិនទាន់មានគេធ្វើឲ្យចិត្តថ្នាំងថ្នាក់ទេ ដូចទឹកក្នុងពាងដែលថ្លាតែខាងលើ ហើយនៅមានកករនៅបាតពាង តែគេធ្វើឲ្យពាងរង្គើនោះកករក៏ឡើងមកលាយឡំធ្វើឲ្យទឹកទៅជាល្អក់មួយរំពេច។ ខ្ញុំនិយាយនេះដោយសំអាងលើពាក្យថា **នត្ថិ សន្តិ បរំ សុខំ** គ្មានសុខអ្វី ស្មើនឹងសេចក្តីស្ងប់ ដូច្នេះក្នុងរសនិព្វាន មានសេចក្តីស្ងប់មួយដែរ ។ ដូចគេថាស្ករផ្អែម ផ្អែមរបស់ស្ករត្នោត ក៏ជារសផ្អែមមួយដែរ ហើយរសស្ករអំពៅ ជារសផ្អែមមួយទៀត ដូច្នេះ សេចក្តីស្ងប់ ក៏ជារសមួយនៃនិព្វានដែរ ។ មានសំណួរមួយដែលសួរថា និព្វាន ជា វិសង្ខារធម៌ (នេះតាមធម៌ព្រះ) ចុះព្រះអរហន្តបានសម្រេចនិព្វានម្តេចនឹងកើត បើលោកនៅមាន ខន្ធ៥ ( រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ដូចយើងដែរ ហើយខន្ធ៥ក៏ជាសង្ខារធម៌ដែរ ។ ជាការពិតហើយដែលថាព្រះអរហន្តនៅមានខន្ធ៥នៅឡើយ តែចិត្តព្រះអរហន្តខុសពីចិត្តយើងដែលជាបុថុជ្ជន ត្រង់ចិត្តលោកបរិសុទ្ធ អស់កិលេស ទាំងកិលេសគ្រោតគ្រាត ទាំងកិលេសល្អិតសុខុម ។ ដោយហេតុព្រះអរហន្តនៅមាន សង្ខារធម៌ជាប់មកពីកំណើតនេះហើយ បានមានពាក្យ

**បរិនិព្វាន** គឺ និព្វានទៅម្ខាង ពីនិព្វានដែលមានសង្ខារធម៌នៅឡើយ គឺ ជានិព្វាន មិនមានការកើតទៀត។ពីព្រោះតែមានការកើតហើយ ក្នុងកំណើតនោះ ត្រូវតែ មានសង្ខារធម៌មកជាប់ជាមួយម្តងទៀត ។ដូច្នេះដើម្បីបានសម្រេចនិព្វានជា វិសង្ខារធម៌ នោះទាល់តែព្រះអរហន្តបានរំលាយខន្ធពីភពទាំងបីនេះទៅ គឺ កាមភព រូបភព និង អរូបភព ។

<u>២- ត្រូវរស់នៅឲ្យស្របទៅតាមច្បាប់ធម្មជាតិ</u>

យើងពុំអាចកែច្បាប់ធម្មជាតិ ឲ្យស្របមកតាមចិត្តយើងបានទេ ។ ឧបមា ថាយើងមិនចង់ ឲ្យមេឃភ្លៀងទេថ្ងៃនេះ ពីព្រោះយើងធ្វើបុណ្យមានភ្ញៀវច្រើន។ តែមេឃមិនបានស្តាប់ យើងទេ ។ ដូច្នេះ យើងទេដែលត្រូវ សម្របទៅតាមច្បាប់ធម្មជាតិ ។ បើយើងស្គាល់ច្បាប់ ធម្មជាតិច្បាស់ យើងអាចទាញយកផលប្រយោជន៍ពីច្បាប់នេះ ឬក៏អាចចៀសនូវគ្រោះ ថ្នាក់បណ្តាលមកពីច្បាប់នេះដែរ ។ តែឲ្យច្បាប់នេះ កែមកតាមយើងគឺមិនបានឡើយ ។ អាចទាញយកប្រយោជន៍ ដូចជា យើងត្រូវការទឹកភ្លៀង ដើម្បីដាំស្រូវ ។ ចៀសនូវគ្រោះ ថ្នាក់ដូចជា យន្តហោះបើដឹងថាតំបន់ដែលនឹងត្រូវហោះកាត់មានខ្យល់ព្យុះខ្លាំង នោះ អ្នកបើកយន្តហោះ មានពេលនឹងគេចពីតំបន់នោះ ។

ច្បាប់ធម្មជាតិមួយ ដែលយើងត្រូវស្របតាម គឺច្បាប់ អនិច្ចំ ដែលថា មិនទៀង ដូចជា ជីវិត មិនទៀងជាដើម ។ ន័យមួយទៀតគឺ ផ្លាស់ប្តូរ ប្រែប្រួល ដូចជា សំលៀកបំពាក់ត្រូវ ផ្លាស់ប្តូរទៅតាមរដូវ រងារ ឬ ក្តៅ ឬ ទៅតាមម៉ូត ទៅតាមសម័យ ។ នេះមកពីចិត្តមនុស្ស ផ្លាស់ប្តូរ របស់នៅជុំវិញយើង ផ្លាស់ប្តូរ ប្រទេសជិតខាងគេផ្លាស់ប្តូរ ដូច្នេះយើងត្រូវតែ ផ្លាស់ប្តូរ ទៅរកវឌ្ឍនភាព ដូចគេឯងដែរ ។ មានសុភាសិត ចិនមួយថា « ដែលភ័យ គឺ ភ័យមិនទៅមុខ តែបើទៅមុខហើយ ទោះបីជាយឺតក៏មិនអីដែរ » ហើយសុភាសិតបារាំង មួយថា « កាលណាមិនទៅមុខ នោះថយក្រោយហើយ » (ពីព្រោះនៅពេលជាមួយ

គ្នានោះ មានគេឯទៀតគេទៅមុខ) ។

មកដល់ត្រង់នេះ ខ្ញុំនឹកឃើញសំណួរមួយ ដែលខ្ញុំកាលពីក្មេងបាន សួរទៅឪពុកខ្ញុំថា « លោកតា បានគិម កាលពីដើម គាត់ជាអ្នកមានទ្រព្យសម្បត្តិ មួយនៅឃុំបាក់ខែង យើង ហេតុអ្វីបានជា សព្វថ្ងៃនេះ គាត់គ្រាន់តែជាអ្នកធម្មតា ? » ។ ឪពុកខ្ញុំឆ្លើយ មកខ្ញុំថា « មកពីមុខរបរ ដែលគាត់រកកាលពីមុននោះ ឥឡូវនេះគេប្រើសុទ្ធតែម៉ាស៊ីនដូច ជាគេប្រើកាណូត ហើយគាត់នៅប្រើទូកចែវ ជាដើម ពោលគឺគាត់ធ្វើការវិវឌ្ឍន៍មិន ទាន់ពេលវេលា » ។ នេះជាឧទាហរណ៍មួយ ដែលអ្នកដឹកនាំគួរយកមកពិចារណា ។

<u>៣- រឿង កើតពីហេតុ</u>

មនុស្សយើងគ្រប់រូប សុទ្ធតែចង់បានសុខ មិនចង់ជួបប្រទះ នឹងរឿងរ៉ាវផ្សេងៗនោះទេ ។ ដោយរឿងរ៉ាវខ្លះកើតមកពីក្រៅ មិនមែនយើងជាអ្នកបង្កើត តើត្រូវធ្វើដូចម្តេច ដើម្បីកុំឲ្យ រឿងទាំងនោះមករំខានយើង ។ របៀបម្យ៉ាងដើម្បីជៀសវាង គឺត្រូវដោះស្រាយកុំបង្អែ បង្អង់ ទុកឲ្យរឿងនោះកាន់តែធំឡើងៗ ដោយឆាប់រកហេតុវាឲ្យឃើញ ។ ពីព្រោះរឿង មិនងាយរលត់ទៅវិញឯងៗទេ លុះត្រាតែហេតុរលត់ ទើបរឿងនោះរលត់ ។

យើងអាចយកក្បួននេះ មកអនុវត្តលើការងារដែលយើងត្រូវធ្វើ ក្នុងជីវិតរស់នៅសព្វ ថ្ងៃនេះ ។ ការងារដែលត្រូវធ្វើ គួរតែធ្វើឲ្យហើយកុំបង្អង់ ។ ពីព្រោះបើយើងមិនធ្វើ នៅពេលនេះ ក៏គេចមិនរួចនៅពេលខាងមុខដែរ ។ ដោយធ្វើរបៀបនេះ យើងជៀសវាង ការកើតទុក្ខ ព្រោះតែកិច្ចការដែលកកកុញនោះ ដល់ច្រើនទៅវាមកគ្របសង្កត់លើយើង។ ដូចពាក្យលោកថា « កុំទុកទៅថ្ងៃស្អែក កិច្ចការអ្វីដែលអាចធ្វើនៅថ្ងៃនេះបាន »។ យើង អាចទុកកិច្ចការដូចជា ទម្ងន់មួយ ហើយបើយើងមិនយកទម្ងន់នោះចេញទេ ទម្ងន់ថ្មី មកថែមពីលើវា ហើយដល់យូរៗទៅ យើងកាន់តែធ្ងន់ ងើបលែងរួច ត្រូវហៅគេមកជួយ ។

## ៤- តើត្រូវធ្វើដូចម្តេច ដើម្បីអ្នកដទៃ គេស្រឡាញ់ គោរព រាប់អានយើង

មនុស្សយើងធ្វើអំពើទាំងពួងដោយ  កាយ វាចា និង ចិត្ត ។ ចំពោះសុខនិងទុក្ខ ទាំង យើងទាំងគេ សុទ្ធតែចង់បានសុខ ហើយ មិនចង់ជួបនឹងទុក្ខ ។

ដូច្នេះមុននឹងធ្វើអំពើអ្វីមួយ យើងត្រូវគិតថា បើគេធ្វើអំពើបែបនេះមកលើយើង តើយើង សប្បាយចិត្ត ឬ កើតទុក្ខ ?

បើយើងឆ្លើយថា យើងនឹងសប្បាយចិត្ត នោះយើងធ្វើទៅលើគេ  គេនឹងសប្បាយចិត្តដូច យើងដែរ ។ដូច្នេះបើយើងធ្វើអំពើនោះទៅ អ្នកផងទាំងពួងគេនឹង  គោរព ស្រឡាញ់ រាប់អានយើងហើយ ។ តែបើយើងឆ្លើយថា យើងក៏មិនចង់ឲ្យគេធ្វើមកលើយើងរបៀប នេះដែរ  នោះយើងកុំធ្វើអំពើនោះទៅលើគេ ។ ប្រសិនបើជាយើងធ្វើវិញ នោះគេនឹង មួម៉ៅពីព្រោះគេខាតប្រយោជន៍ រងទុក្ខវេទនាដោយ ព្រោះតែអំពើរបស់យើង។

ខ្ញុំលើកយករឿងនេះមកនិយាយពេលនេះ  ដោយខ្ញុំសង្កេតឃើញអ្នកខ្លះចង់ឲ្យគេគោរព ស្រឡាញ់រាប់អាន  តែអ្នកនោះ ធ្វើតែអំពើអ្វី ដែលមិនគួរឲ្យគេស្រឡាញ់រាប់អានបាន ដូចជា គិតតែប្រយោជន៍ផ្ទាល់ខ្លួន ចង់អ្នកណាស្លាប់ក៏ស្លាប់ទៅ  ឲ្យតែអាត្មាអញ គ្រួសារ អញ  មិត្តភក្តិអញ បានចម្រើន សុខសប្បាយ ។ ដូចអ្នកដឹកនាំប្រទេសខ្លះ មករំលោភ ឈ្លានពានប្រទេសទន់ខ្សោយជាងខ្លួន ដើម្បីប្រមូលទ្រព្យសម្បត្តិប្រទេសគេ យកទៅ ឲ្យប្រជារាស្ត្រខ្លួន ។  ចុះម្តេចក៏មិនគិតថា ប្រជារាស្ត្រយើងចង់សុខ ចម្រុងចម្រើន  ប្រជារាស្ត្រគេ  ក៏ចង់សុខចម្រុងចម្រើនដែរ ។ បើគិតរបៀបនេះ  នោះយើងនិងគេ នឹងបាន សុខសប្បាយទាំងអស់គ្នា ។ ពីព្រោះថា បើយើងបានសុខ ហើយគេមិនបានសុខ  នោះមិន យូរ មិនឆាប់ យើងក៏នឹងមិនបានសុខដែរ ។

៥- ត្រូវស្គាល់ ហេតុ ផល

ធម៌ « ហេតុផល » មានប្រយោជន៍ច្រើនក្នុងការដោះស្រាយចំណោទផ្សេងៗ ។ ដូចជាម៉ាស៊ីនរថយន្តខូច ដាំងដើម្បីធ្វើម៉ាស៊ីនរថយន្តនោះឲ្យដើរឡើងវិញ ត្រូវស្គាល់ហេតុ ដែលនាំឲ្យ ម៉ាស៊ីននោះមិនដើរ ។ ដោយម៉ាស៊ីនមិនចេះនិយាយ [1] ដាំងត្រូវរកហេតុនោះឲ្យឃើញជាមុនសិនទើបអាចជួសជុលម៉ាស៊ីននោះបាន ។ ការរកហេតុនេះដោយពឹងផ្អែកទៅលើ ការសមហេតុ សមផល (ឬ ហេតុ បច្ច័យ) គឺ បើ « ក » => « ខ » => « គ » => « ឃ » នោះគេរកហេតុដើមដំបូង ដោយដេញមករកមូលហេតុ ដូចតទៅ ៖ គេសួរថាតើ « ឃ » (ម៉ាស៊ីនរថយន្តមិនឆេះ) មកពីហេតុអ្វី ? ដល់រកទៅគេឃើញថាមកពី « គ »។ រួចហើយ គេសួរដេញតទៅទៀតថា តើ « គ » មានមកពីហេតុអ្វី ? ដល់រកទៅគេឃើញថា មកពី « ខ »។ ហើយដល់សួរ ថា « ខ » ចេញមកពីណា ? នោះគេឃើញថា មកពី « ក » ។ ដូច្នេះហេតុដែលធំ ដែលដំបូងគេ គឺ « ក » ។ បើកាលណាដាំងនោះជួសជុល « ក » ទៅ ចំណោទនោះក៏ដោះស្រាយបានដូចបំណាំង ។ ការរកហេតុដើមនៃចំណោទខ្លះ មិនជាស្រួលទេ ។ ដូចសព្វថ្ងៃនេះ ចំណោទយុវជនអត់ការងារធ្វើ តើដោយហេតុអ្វី ជាដើម ។ តែក៏មានចំណោទជាច្រើនដែលអាចរកហេតុឃើញដោយមិនពិបាក ប្រសិនបើជាគេចង់ដោះស្រាយចំណោទនោះដោយចិត្តស្មោះត្រង់ពិតមែនៗ ដូចជាចំណោទ អំពើពុករលួយ ជាដើម ។ យើងច្រើនសង្កេតឃើញនៅក្នុងប្រទេសក្រីក្រដែលប្រជាជនមិនសូវចេះដឹង មានអំពើពុករលួយ ច្រើនជាងប្រទេសជឿនលឿនៗ បើអ្នកដឹកនាំប្រទេសក្រីក្រ ចង់ដោះស្រាយបញ្ហានោះដោយ

[1] មិនដូចគ្រូពេទ្យ ដែលសួរអ្នកជម្ងឺ ដែលចេះនិយាយ ។យ៉ាងនេះហើយក៏នៅធ្វើ រ៉ាឌីយោ (radio) ឬ ស្កានណែ (Scanner) ថែមទៀត ។

ពិតប្រាកដ នោះគប្បីរកហេតុ ដែលនាំឲ្យមានអំពើពុករលួយតិច នៅក្នុងប្រទេសជឿនលឿន នឹងហេតុដែលនាំឲ្យមានអំពើពុករលួយច្រើន នៅប្រទេសក្រីក្រ ។

បន្ទាប់មក យើងយកហេតុទាំងពីរមកប្រៀបធៀបនឹងគ្នា តើហេតុទាំងពីរនោះ ខុសគ្នាត្រង់ណាខ្លះ ហើយយើងកែហេតុដែលនាំឲ្យមានអំពើពុករលួយទៅតាមនោះទៅ ។ ធ្វើរបៀបនេះ ត្រូវនឹងធម៌ព្រះពុទ្ធ ដែលថែងថា **ធម៌ទាំងឡាយកើតមកអំពីហេតុ កាលណាហេតុរលត់ ធម៌នោះក៏រលត់** ។ មុននឹងបញ្ចប់ អត្ថបទនេះ ខ្ញុំសូមដំណាលរឿងមួយដែលជារឿងពិត នៅភូមិខ្ញុំ ។ កាលនោះខ្ញុំនៅក្មេងនៅឡើយ មានប្តីប្រពន្ធពីរនាក់ ប្តីអាយុប្រហែល ២២ ឆ្នាំ ហើយប្រពន្ធ ប្រហែល ១៨ឆ្នាំ មានរូបរាង ស្អាតល្អទាំងពីរនាក់ ហើយរស់នៅជាមួយគ្នាដោយសុខសាន្ត ។ កាលដើមឡើយប្តីធ្វើការនៅសហគ្រាសរដ្ឋ ឈ្មោះ SKD (Société Khmer de Distillerie) ដល់ក្រោយមក មកដើរកាណូតដឹកជញ្ជូនអីវ៉ាន់ មកលក់នៅភ្នំពេញ ។ ថ្ងៃមួយ ប្តីនៅពេលបញ្ឆេះម៉ាស៊ីនកាណូតមិនឆេះ ក៏ខឹងហើយយកជើងទៅធាក់ម៉ាស៊ីនមួយជើងយ៉ាងខ្លាំង ក៏ធ្វើឲ្យរបួសជើង ។ ដល់ក្រោយមក របួសនោះក្លាយទៅជាដំបៅ រហូតដល់ទៅសុំឲ្យគ្រូពេទ្យកាត់ជើងនោះចេញ ។ ប្តីនោះក្លាយទៅជាអ្នកពិការ រកទទួលទានដោយប៉ះកង់។ ប្រពន្ធគេក៏ឈប់ស្រឡាញ់ លែងលះគ្នា ហើយគេក៏ទៅរៀបការជាមួយនឹងកម្លោះមួយនៅក្នុងភូមិដដែល ។ ខ្ញុំលើករឿងនេះមកនិទាន មកពីខ្ញុំពីក្មេង នៅរៀននៅសាលាមបឋមសិក្សានៅឡើយ មានថ្ងៃមួយនោះខ្ញុំងើបពីព្រលឹម ដើម្បីមើលមេរៀនឡើងវិញ មុននឹងទៅសាលា ។ ដោយនៅស្រុកចំការ ត្រូវអុជចង្កៀងប្រេងកាត ដើម្បីមើលមេរៀន ដល់ខ្ញុំកេះ ដែកកេះចេះតែមិនឆេះ ខ្ញុំក៏បោកដែកកេះចោល។ ឪពុកខ្ញុំឮ ក៏ពោលថា « ទៅខឹងអីនឹងដែកកេះ ដែលជារបស់ឥតវិញ្ញាណ »។ នេះហើយដូចពាក្យចាស់លោកថា « ខឹងគោ វាយរទេះ » អត់បំណោញបានតែខាត ដូចអ្នកពិការនោះ អស់ទាំងជើង អស់ទាំងប្រពន្ធក្មេង។

ដោយប្រើច្បាប់ **ធម៌ទាំងឡាយកើតមកអំពីហេតុ** ខ្ញុំចេះជួសជុលរបស់ដែលខូច បានច្រើន ដោយមិនចាំបាច់ហៅជាងមកធ្វើ ។ នេះកាលណាខ្ញុំអាចដោះបើកគំរប របស់នោះបាន ខ្ញុំមើលកន្លែងដែលវាខូច ហើយរកហេតុដែលនាំឲ្យខូច ។បើកាលណាខ្ញុំឃើញហេតុហើយ នោះខ្ញុំអាចជួសជុលបាន ដោយមិនចាំបាច់ទៅទិញរបស់ថ្មីមកផ្លាស់ក៏មាន។ ដើម្បីបំបាត់អំពើពុករលួយបានដោយប្រសិទ្ធិភាព ទាល់តែបំបាត់ហេតុដើមដែលធ្វើឲ្យមនុស្សទូទៅច្រើនតែពុករលួយ ។ តាមខ្ញុំយល់មិនមែនយកច្បាប់ខាងផ្លូវលោកមកប្រើ ដូចជាពិន័យ ឬចាប់ដាក់គុកជាដើមនោះទេ តែត្រូវយកច្បាប់ខាងផ្លូវធម៌មកពន្យល់វិញ គឺធ្វើឲ្យអ្នកទាំងនោះយល់ដោយខ្លួនឯងថា ទ្រព្យសម្បត្តិលុយកាក់មាសពេជ្រ មិនផ្តល់ឲ្យមានសុភមង្គលរហូតទេ តែសុភមង្គលដែលពិតនោះ គឺកាលណាចិត្តយើងស្ងប់ មិនព្រួយបារម្ភ មិនដូចចិត្តពួកចោរ ឬពួករត់គ្រឿងញៀនជាដើម ។

<u>៦- ខ្លួនទីពឹងខ្លួន</u>

ដើម្បីកុំឲ្យខកចិត្ត មុននឹងធ្វើការអ្វីមួយ ត្រូវមើលកម្លាំងរបស់ខ្លួនជាមុនសិន កុំអាលសង្ឃឹមទៅលើកម្លាំងអ្នកដទៃ ។ ពោលគឺថា បើគេមិនជួយ ក៏ការរបស់យើងនៅតែដើរ គ្រាន់តែមិនបានលឿនដូចគេជួយ ។ ម្យ៉ាងទៀតទុកជាគេជួយ ក៏គេជួយបានតែមួយគ្រា ឬ ពីរគ្រាតែប៉ុណ្ណោះ គេមិនអាចជួយយើងរហូតទេ ។

<u>៧- ត្រូវដើរផ្លូវកណ្តាល</u>

ដើរផ្លូវកណ្តាល មិនមែនព្រោះតែ មិនច្បាស់ខ្លួនឯង ដូចជាការបោះឆ្នោតស (អត់យោបល់) នោះទេ ។ ពាក្យថា កណ្តាល គឺកុំឲ្យហួសជ្រុលពីម្ខាងទៅម្ខាង ដូចជាកុំឲ្យតឹងពេក កុំឲ្យធូរពេក ។ ព្រះពុទ្ធ មុននឹងបានត្រាស់ដឹង ព្រះអង្គកាន់តឹងពេក ធ្វើទុក្ខកិរិយា នោះទៅជារកធម៌សម្រេចនិព្វានមិនឃើញទៅវិញ ដល់ព្រះអង្គទ្រង់កាន់ផ្លូវកណ្តាលទើបរកធម៌នោះឃើញ។ ក្នុងជីវិតយើងរស់នៅសព្វថ្ងៃនេះ ក៏គប្បីដើរផ្លូវ

កណ្ដាលនេះដែរ ។ មានអ្នកខ្លះខំធ្វើការផ្សារខ្លាំងពេក ដល់ពេលចូលនិវត្ត ទៅជាមានជម្ងឺដោយបាក់កម្លាំង ។ អ្នកខ្លះដោយខ្លួនឯងខ្ជិលធ្វើការ ខ្វះការព្យាយាម និយាយថាធម៌ព្រះ មិនឲ្យលោភ ។ ពាក្យប្រៀនប្រដៅ ជា ក្បួនមួយទូទៅ ដើម្បីយកទៅអនុវត្តយើងត្រូវចេះយកមកតម្រូវតាមកម្លាំងយើងម្នាក់ៗ ។ ដូចអ្នកខ្លះគេលីបារអង្ករទម្ងន់ ៥០ kg បាន ហើយបើយើងលីបានតែត្រឹម២៥ kg នោះទៅលីបារទម្ងន់ ៥០ kg ដូចគេ ទៅជាមានគ្រោះថ្នាក់ដល់ខ្លួនយើងទៅវិញ ។

<u>៨- ត្រូវទទួលស្គាល់កំហុសរបស់ខ្លួន - សម្មប្បធាន៤</u>

មនុស្សយើង តែងតែមានកំហុស ។ មនុស្សដែលគ្មានកំហុសសោះពិបាកនឹងរកណាស់ ។ ដូច្នេះបើយើងធ្វើខុស មិនមានអ្វីប្លែកទេ ត្រូវហ៊ាន ទទួលស្គាល់កំហុសនោះ ដើម្បីនឹងកែទៅថ្ងៃមុខ ។ ធ្វើបែបនេះត្រូវនឹង ពាក្យទូន្មានរបស់ព្រះពុទ្ធក្នុងធម៌ សម្មប្បធាន៤ ដែលចែងថា ៖

១- ព្យាយាម កុំធ្វើតទៅទៀតនូវ អំពើអកុសល ដែលបានធ្វើហើយ ។

២- ព្យាយាម កុំធ្វើ អំពើអកុសលដែល មិនទាន់បានធ្វើ ។

៣- ព្យាយាម រក្សាអំពើកុសល ដែលបានធ្វើហើយ និង ខំធ្វើអំពើកុសលនោះតទៅទៀតឲ្យកាន់តែច្រើន។

៤- ព្យាយាម ខំធ្វើអំពើកុសលដែល មិនទាន់បានធ្វើ ។

<u>៩- គប្បីទទួលយកធម៌ព្រះពុទ្ធមកដាក់ក្នុងខ្លួនកុំបង្អែបង្អង់</u>

មានអ្នកខ្លះធ្វើបុណ្យប្រាថ្នាឲ្យបានជួបព្រះពុទ្ធអនាគត ព្រះនាម **មេត្រី** ។ ខ្ញុំសួរថា ចង់ជួបដើម្បី ប្រយោជន៍អ្វី ? បើថា « ចង់ជួបដើម្បីស្គាល់ធម៌ព្រះមេត្រី ឬ ដើម្បីទៅអនាគតបានត្រាស់ជាព្រះពុទ្ធមួយអង្គ ឬ មួយដើម្បីបានសម្រេចជាព្រះអរហន្ត » នោះខ្ញុំសូមជូនយោបល់ដូចតទៅ ៖

1- <u>ចង់ស្គាល់ធម៌ព្រះ មេត្រី</u> សព្វថ្ងៃនេះយើងមានធម៌ព្រះពុទ្ធស្រាប់ហើយ ម្តេចក៏មិនខំរៀន មិនខំបដិបត្តិទៅ ? ម្តេចក៏ទៅចាំរបស់ដែលមិនទាន់មកដល់ទៅវិញ ? ក្រែងដល់ពេលនោះមិនបានកើតជាមនុស្ស ហើយជួនកាលកើតជាមនុស្សហើយ ក៏អាចមិនជួបនឹងព្រះក៏មានដែរ ពីព្រោះប្រទេសឥណ្ឌាធំ ។ នៅជំនាន់ព្រះគោតម ក៏មានអ្នកខ្លះមិនបានជួបព្រះអង្គដែរ ពីព្រោះ រស់នៅឆ្ងាយពីកន្លែងដែលព្រះអង្គគង់នៅ ឬមួយមិនបានស្គាល់ធម៌ព្រះអង្គក៏មានដែរ ពីព្រោះមានមិច្ឆាទិដ្ឋិ ។

2- <u>ចង់បានត្រាស់ជាព្រះពុទ្ធ</u> បំណងនេះល្អបំផុត តែគប្បីចាប់ជួយប្រោសសត្វលោកចាប់ពីពេលនេះទៅ ពីព្រោះព្រះពុទ្ធគោតម ព្រះអង្គខំកសាងក៏ដើម្បីបានត្រាស់ដឹងនូវធម៌សម្រាប់ប្រោសសត្វលោកឲ្យរួចចាកទុក្ខដែរ ។ ឥឡូវនេះធម៌ប្រោសសត្វលោកឲ្យរួចចាកទុក្ខនោះមានហើយ ដូច្នេះគ្រាន់តែយកធម៌នោះទៅផ្សព្វផ្សាយពន្យល់ទៅក៏ដូចជាបានត្រាស់ជាព្រះពុទ្ធដែរ ។ ម្តេចចាំទាល់តែធម៌របស់យើងបានពូកែ ? គំនិតរបៀបនេះខ្ញុំធ្លាប់ជួបហើយនៅកន្លែងធ្វើការ ចំពោះមេៗខ្លះ ទាល់តែគំនិតរបស់គេដែលជាមេ បានគេយក បើគំនិតមកពីកូនចៅ គេមិនយកទេ ទុកជាល្អជាងគំនិតខ្លួនក៏ដោយ នេះហើយហៅថាអញ្ញនិយម ។

3- <u>ចង់បានសម្រេចជាព្រះអរហន្ត</u> សូមជំរាបថា កាលជំនាន់ព្រះពុទ្ធគោតម ក៏មានអ្នកដែលមិនបានសម្រេចជាព្រះអរហន្តដែរ ។ យើងឃើញសាវកព្រះខ្លះបានសម្រេចជាព្រះអរហន្តពិតមែន តែយើងដឹងទេ ការកសាងកាលពីអតីតជាតិនៃសាវកទាំងនោះ ? ឆ្លើយថាយើងពុំអាចដឹងទេ ។

រួមសេចក្តីទៅ នៅពេលនេះយើងមានសំណាងបានជួបនឹងធម៌ព្រះហើយ ត្រូវខំបដិបត្តិតាមធម៌ព្រះអង្គឲ្យបានជាប់ជានិច្ច ទាន់កម្លាំងស្មារតីនៅមាន ។